ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ លេខៈ **៧៦៥ អក**
ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៦
សាលក្រមលេខៈ **០១៤ (ណ)**
ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជំនុំជម្រះសាធារណៈ នៅសាលាដំបូងខេត្តកណ្តាល នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ដោយមានសមាសភាពដូចតទៅ:

### សមាសភាពជំនុំជំរះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោកស្រី [redacted] ចៅក្រម ប្រឹក្សា
លោក [redacted] ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

### ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជី សាលាដំបូងខេត្តកណ្តាល

### មេធាវី

លោក [redacted] មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ផល្លា
លោកស្រី [redacted] មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ផល្លា

**ដើម្បីជំនុំជំរះ** សំណុំរឿងព្រហ្មទណ្ឌលេខៈ **៧៦៥ អក** ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទៈ

-ឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិកោះរះលើ ឃុំកោះរះ ស្រុកល្វាឯម ខេត្តកណ្តាល ជានីតិជន (**ក្រៅឃុំ**)។

ត្រូវជាប់ចោទពីបទៈ **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២៧** និងមាត្រា **១៩៩** នៃ**ក្រមព្រហ្មទណ្ឌ**។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ីតឡី** ភេទប្រុស អាយុ ៣៣ឆ្នាំ មុខរបរ លក់គ្រឿងសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ផេង (ស្លាប់) ម្តាយឈ្មោះ [redacted] សាត (ស្លាប់) ប្រពន្ធឈ្មោះ [redacted] សុឡា មានកូន ០២នាក់ ជានីតិជន។

**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ៖ **៨៤២** ដកសព ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

**បានឃើញ** ដីកាដំណោះស្រាយលេខ៖ **៨៩៥** ដកជស ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៩ របស់ចៅក្រុមស៊ើបសួរ សាលាដំបូងខេត្តកណ្ដាល ។

**បានឃើញ** ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៖ **៩៩១** ដកចត ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩ របស់ប្រធានសាលាដំបូងខេត្តកណ្ដាល ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទ

កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ មានករណី ប៉ុនប៉ងឃាតកម្ម ប្រព្រឹត្តនៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្ដាល បង្កឡើងដោយឈ្មោះ[redacted]ផល្លា ហៅ **អាស្លឹក** បានផឹកស្រាស្រវឹង ហើយយកគល់ឫស្សីមកវាយទៅលើជនរងគ្រោះឈ្មោះ[redacted] **ប៊ីតឡី** ពីក្រោយតែត្រូវបានជនរងគ្រោះឃើញទាន់ក៏បានរត់គេចខ្លួន បានបន្តិចក្រោយមកឈ្មោះ[redacted]ផល្លា ហៅ **អាស្លឹក** បានយកកាំបិតផ្គាក់ដេញតាមកាប់ជនរងគ្រោះទៀត តែជនរងគ្រោះបានរត់គេចទៅពួននៅផ្ទះអ្នកស្រុក បន្ទាប់ពីធ្វើសកម្មភាពរួច ជនល្មើសបានរត់គេចខ្លួនបាត់។

## នាពេលសវនាការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

-ក្រោយពីបានស្ដាប់អំណានរបាយការណ៍របស់មន្ត្រីនគរបាល

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានពិនិត្យសំណុំរឿងចប់សព្វគ្រប់

## សាលាដំបូងខេត្តកណ្ដាល
## យល់ឃើញថា

### ក.អំពីពិរុទ្ធភាព៖

១-តាមដីកាដំណោះស្រាយលេខ **៨៩៥** ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៩ របស់ ចៅក្រុមស៊ើបសួរនៃសាលាដំបូងខេត្តកណ្ដាល ដែលបានបញ្ជូនជនជាប់ចោទឈ្មោះ[redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ មកតុលាការដើម្បីជំនុំជម្រះពីបទ៖ **ប៉ុនប៉ងឃាតកម្ម** ប្រព្រឹត្តនៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្ដាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ បញ្ញត្តិផ្ទន្ទាទោសតាមមាត្រា **២៧** និងមាត្រា **១៩៩** នៃ**ក្រមព្រហ្មទណ្ឌ។**

២-តាមចម្លើយដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ីតឡី** បានឆ្លើយថា៖ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោងប្រហែលជាង ០៦រសៀល ខ្លួន និងកម្មកររបស់ខ្លួនត្រឡប់ពីដឹកលូឱ្យគេវិញ ក៏បានឃើញឈ្មោះ [redacted] ផល្លា ហៅ អាស្លឹក អង្គុយផឹកស្រាជាមួយនឹងបក្សពួក ០៣នាក់ទៀត ហើយឈ្មោះ [redacted] ផល្លា បានហៅខ្លួនផឹកស្រាជាមួយ ប៉ុន្តែមិនទាន់បានផឹកផង ស្រាប់តែឈ្មោះ [redacted] ផល្លា ហៅ អាស្លឹក បានយកគល់ឫស្សីមកវាយខ្លួនពីក្រោយ តែខ្លួនឃើញទាន់ក៏បានរត់ទៅផ្ទះអ្នកស្រុក ហើយកម្មកររបស់ខ្លួនបានយករ៉ឺម៉កមកដឹកខ្លួន ហើយពេលជិះរ៉ឺម៉កបានបន្តិចឈ្មោះ [redacted] ផល្លា បានយកកាំបិតផ្គាក់ដេញកាប់ខ្លួនទៀត ប៉ុន្តែខ្លួនបានរត់ចូលទៅផ្ទះអ្នកស្រុក។



Scanned with CamScanner

៣-តាមរបាយការណ៍របស់មន្ត្រីនគរបាលបានបញ្ជាក់ថា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ពិតជាមានករណី **ប៉ុនប៉ងឃាតកម្ម** កើតឡើងនៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល បង្កដោយឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ពិតប្រាកដមែន។

៤-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ៖ ឆ្លងកាត់អង្គសវនាការនេះ ក្នុងនាមខ្ញុំជាមេធាវីការពារឱ្យជនជាប់ចោទសូមធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីរបស់ខ្ញុំបានប្រព្រឹត្តអំពើវាយទៅលើជនរងគ្រោះមែន ប៉ុន្តែមុនពេលប្រព្រឹត្តនេះ កូនក្តីរបស់ខ្ញុំ និងជនរងគ្រោះជាមនុស្សស្គាល់គ្នា ហើយមានការរាប់អានគ្នា ដោយសារនៅពេលកើតហេតុជនរងគ្រោះ និងកូនក្តីរបស់ខ្ញុំផឹកស៊ីជាមួយគ្នា ហើយទ្បាប់មកកូនក្តីរបស់ខ្ញុំក៏មានការទាស់សម្តីគ្នា ហើយក៏បានវាយទៅលើជនរងគ្រោះមួយដំបងឫស្សីពីក្រោយដោយមានការទាស់សម្តីនឹងគ្នា។ ក្នុងរឿងនេះកូនក្តីរបស់ខ្ញុំពុំមានចេតនាវាយទៅលើជនរងគ្រោះទេ។ ហើយតំណាងអយ្យការបានបើកការស៊ើបអង្កេតពីបទ៖ ប៉ុនប៉ងឃាតកម្ម តាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ តាមអង្គហេតុនេះកូនក្តីរបស់ខ្ញុំគ្មានចេតនាវាយទៅលើជនរងគ្រោះទេ ហេតុដូច្នេះស្នើសុំដល់លោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ និងចៅក្រមប្រឹក្សាជួយកែប្រែបទចោទពីបទៈ ប៉ុនប៉ងឃាតកម្ម ទៅជាបទៈ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស វិញ ហើយសូមឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះជួយបន្ធូរបន្ថយទោសឱ្យកូនក្តីរបស់ខ្ញុំផង។

៥-តំណាងអយ្យការបានសន្និដ្ឋានថា៖ តាមអង្គសវនាការ និងការពិនិត្យលើសំណុំរឿងបង្ហាញថា ជនជាប់ចោទបានវាយទៅជនរងគ្រោះចំនួនមួយដំបងឫស្សី ដោយសារតែជនជាប់ចោទ និងជនរងគ្រោះបានទាស់ពាក្យសំដីនឹងគ្នា ទើបបណ្តាលឱ្យជនជាប់ចោទមានការខឹងនឹងជនរងគ្រោះ ហេតុដូច្នេះ តំណាងអយ្យការសូមឱ្យលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះ កែប្រែបទចោទពីបទៈ **ប៉ុនប៉ងឃាតកម្ម** តាមមាត្រា **២៧** និងមាត្រា **១៩៩** ទៅជាបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមមាត្រា ២១៨ នៃក្រមព្រហ្មទណ្ឌ វិញ។

៦-តាមអំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី របាយការណ៍របស់មន្ត្រីនគរបាល និងការសន្និដ្ឋានរបស់តំណាងអយ្យការ មានភាពស៊ីចង្វាក់គ្នា សបញ្ជាក់ឱ្យឃើញថា កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ជនជាប់ចោទឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** បានវាយទៅជនរងគ្រោះចំនួនមួយដំបងឫស្សី ដោយសារតែជនជាប់ចោទ និងជនរងគ្រោះបានទាស់ពាក្យសំដីនឹងគ្នា ទើបបណ្តាលឱ្យជនជាប់ចោទមានការខឹងនឹងជនរងគ្រោះ ហេតុដូច្នេះ តុលាការ កែប្រែបទចោទពីបទៈ **ប៉ុនប៉ងឃាតកម្ម** តាមមាត្រា **២៧** និងមាត្រា **១៩៩** ទៅជាបទៈ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ វិញ។

៧-អំពើរបស់ជនជាប់ចោទ គឺជាបទល្មើសព្រហ្មទណ្ឌ និងបានបង្កចលាចលដល់សង្គម និងសណ្តាប់ធ្នាប់សាធារណៈ ដែលអំពើនេះត្រូវ បានសង្គមចាត់ទុកជាអំពើល្មើសផ្នែកព្រហ្មទណ្ឌតាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ។

៨-ជនជាប់ចោទឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ ជានីតិជន មានស្មារតី និងសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវ ចំពោះអំពើរបស់ខ្លួនហើយមានចេតនាពិតប្រាកដក្នុងការប្រព្រឹត្តអំពើខាងលើ។

៩-មានភស្តុតាង ដាក់បន្ទុកគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាពលើឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ (ក្រៅឃុំ) ពីបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ។

**ខ-អំពីសំណង និងជំងឺចិត្ត៖**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ីតឡី** ស្នើសុំទាមទារថ្លៃថ្នាំជម្ងឺចិត្តចំនួន ១០,០០០(មួយម៉ឺន) ដុល្លារអាមេរិច ពីជនជាប់ចោទឈ្មោះ [redacted] **ផល្លា** តុលាការពិចារណាតាមព្យសនកម្មកើតមានឡើង។



Scanned with CamScanner

**ហេតុដូច្នេះ សាលាដំបូងខេត្តកណ្តាល វិនិច្ឆ័យសេចក្តី**

១-កែប្រែបទចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ផល្លា ហៅ **អាស្លឹក** ពីបទ៖ **ប៉ុនប៉ងឃាតកម្ម** តាមមាត្រា **២៧** និងមាត្រា **១៩៩** ទៅជាបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** តាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ។

២-ផ្តន្ទាទោសលើជាប់ចោទឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ (មានសារតាជាតិដូចខាងលើ)ដាក់ពន្ធនាគារកំណត់រយៈពេល ០៣(បី)ឆ្នាំ។

ពីបទ៖ **ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅភូមិសិត្បូ ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ បញ្ញត្តិផ្តន្ទាទោសតាមមាត្រា **២១៨** នៃក្រមព្រហ្មទណ្ឌ។

៣-ចេញដីកាបង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** ភេទប្រុស អាយុ ៣១ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **ផល្លា** សងថ្លៃជម្ងឺចិត្តចំនួន ៤,០០០,០០០(បួនលាន)រៀល ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ប៊ីតឡី** ការទាមទារលើសពីនេះត្រូវបានច្រានចោល។

៥-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **ផល្លា** ហៅ **អាស្លឹក** និងដើមបណ្តឹងឈ្មោះ [redacted] **ប៊ីតឡី**។

ទុកសិទ្ធិឲ្យប្តឹងទាស់ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** | **ហត្ថលេខា និង ត្រា** |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃ...៨កើត ១១ ៣៨......ខែ...មាឃ......ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃទី...០២.....ខែ...០៣.....ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

បានទទួលដំណឹង

ថ្ងៃ...៨កើត ១១ ៣៨.........ខែ...មាឃ...ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

កណ្តាល,ថ្ងៃទី...០២.....ខែ...០៣.....ឆ្នាំ២០២០

**តំណាងអយ្យការ**

[redacted]